តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
<u>សាលក្រម</u>
លេខ ៦៤ គ ចុះថ្ងៃទី ៣០
ខែ ឧសភា ឆ្នាំ ២០០៦
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ១១៣ ចុះថ្ងៃទី ០២
ខែ មីនា ឆ្នាំ ២០០៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### តាងនាមប្រជារាស្ត្រខ្មែរ
### តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] ចៅក្រមតុលាការខេត្ត

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ ១១៣ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦ ដែលមានជនជាប់ចោទ :

១-ឈ្មោះ **គ ឪ** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាម៉ាន ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ កំរិតវប្បធម៌គ្មាន សាសនាព្រះពុទ្ធ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិបុស្ស ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ របរធ្វើស្រែ ។ ឪពុកឈ្មោះ **ហ យ** (រ) ម្តាយឈ្មោះ **ល ហ** (រ) នៅលីវ ទោសពីមុន *គ្មាន* ។

-ចាប់ខ្លួនថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦
-ឃុំខ្លួនថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦

២-ឈ្មោះ **អ អ** ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាម៉ាន ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ កំរិតវប្បធម៌ថ្នាក់ទី ៦ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិបុស្ស ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ របររកស៊ីធ្វើស្រែ ។ ឪពុកឈ្មោះ **អ ស** (រ) ម្តាយឈ្មោះ **ហ ម** (រ) នៅលីវ ទោសពីមុន *គ្មាន* ។

-ចាប់ខ្លួនថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦
-ឃុំខ្លួនថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦

៣-ឈ្មោះ **អ ឧ** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាម៉ាន

*សាលក្រមនេះចូលជាស្ថាពរនៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦*
*ដោយពុំមានគូភាគីណាចូលមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*
*សៀមរាប,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦*
***ចៅក្រមជំនុំជំរះ***
***ហត្ថលេខា និង ត្រា***
[redacted]

ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ កិរិតវប្បធម៌គ្មាន សាសនាព្រះពុទ្ធ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិបុស្ស ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ របររកស៊ីធ្វើស្រែ ។ ឪពុកឈ្មោះ ម អ (ស) ម្ដាយឈ្មោះ ត ម (រ) នៅលីវ ទោសពីមុន *គ្មាន* ។

-ចាប់ខ្លួនថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

-ឃុំខ្លួនថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦

ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិបុស្ស ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ទាំង ០៣រូប ។

ដើមបណ្ដឹងរដ្ឋប្បវេណី-ជនរងគ្រោះឈ្មោះ ទ ជ ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃនៅភូមិតាម៉ាន ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ។

## **ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ**

កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ វេលាម៉ោង ០៧ព្រឹក ឈ្មោះ អ ឧ, ឈ្មោះ អ អ និង ឈ្មោះ គ ឡ បានចូលទៅក្នុងព្រៃអូរអកអំបុក រកចាប់សត្វសេក ។ លុះល្ងាចឡើងម៉ោងប្រហែល ០៥រសៀលបានឈ្មោះទាំង ០៣ខាងលើចេញពីព្រៃមកវិញ ដោយរកចាប់សេកពុំបានក៏ឈ្មោះ អ អ បបួលឈ្មោះ គ ឡ និង ឈ្មោះ អ ឧ ទៅយកគោរបស់ពួខ្លួនទៅលក់យកប្រាក់ចាយ ។ ពេលដើររកឃើញគោ ០៥ក្បាលកំពុងស៊ីស្មៅក្បែរព្រៃដោយគ្មានអ្នកឃ្វាល ក៏នាំគ្នាចាប់ដឹក ឈ្មោះ អ អ ដឹក ០១ក្បាល, ឈ្មោះ គ ឡ ចាប់យកគោ ០២ក្បាលឈ្មោល និង ឈ្មោះ អ ឧ យក ០១ក្បាល ។ គោញី ០១ក្បាលទៀតដើរតាមពេលដឹកគោទាំង ០៤ក្បាលនោះ ។ អ្នកទាំងបីដឹកគោកាត់តាមព្រៃ ហើយសំរាកក្នុងព្រៃ ០១យប់ ។ លុះព្រឹកឡើងបានបន្តដឹកគោទៅទៀតរហូតដល់ភូមិពង្រក៏ឈប់សំរាកនៅក្បែរផ្ទះឈ្មោះ ស ។ ពេលនោះក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្ដង ។ ក្រោយពេលចាប់ខ្លួនបានហើយសមត្ថកិច្ចក៏បានធ្វើការសាកសួរឈ្មោះទាំង ០៣ខាងលើសារភាពថា ខ្លួនពិតជាបានយកគោរបស់ពួខ្លួនមែន ។

## **នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ អ ឧ បានឆ្លើយថា កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ វេលាម៉ោង ០៧ព្រឹក ខ្លួន ឈ្មោះ អ អ និង ឈ្មោះ គ ឡ បានចូលទៅក្នុងព្រៃអូរអកអំបុក ស្ថិតនៅភូមិបុស្ស ឃុំកូនក្រៀល រកចាប់សត្វសេកលក់ ។ លុះល្ងាចឡើងម៉ោងប្រហែល ០៥រសៀលខ្លួនទាំង ០៣នាក់ចេញពីព្រៃមកវិញចាប់សេកពុំបាន ។ ឈ្មោះ អ អ ផ្ដើមបបួលឈ្មោះ គ ឡ និង ខ្លួនទៅយកគោឪពុកមារបស់គេចំនួន ០៥ក្បាលយកទៅលក់ ។ គោទាំង ០៥ ក្បាលកំពុងស៊ីស្មៅក្បែរព្រៃដោយគ្មានអ្នកឃ្វាលទេ ទាំង ០៣នាក់ក៏ចូលទៅចាប់ដឹកគោទាំង ០៥ក្បាលចែកគ្នាដឹក ។ ហើយពួកខ្លួនដឹកគោកាត់តាមព្រៃសំរាកក្នុងព្រៃ ០១យប់ ។ លុះព្រឹកឡើងបានបន្តដឹកគោទៅទៀត រហូតដល់ភូមិពង្រក៏ឈប់សំរាកនៅក្បែរផ្ទះឈ្មោះ ស ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង ។

ជនជាប់ចោទឈ្មោះ អ អ បានឆ្លើយថា កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ វេលាម៉ោង ០៧ព្រឹក ឈ្មោះ អ ឧ, ឈ្មោះ គ ឡ និង ខ្លួនបាននាំគ្នាចូលទៅក្នុងព្រៃអូរអកអំបុក ស្ថិតនៅភូមិបុស្ស ឃុំកូនក្រៀល ក្នុងគោលបំណងទៅរកចាប់សត្វសេកលក់ ។ លុះល្ងាចឡើងម៉ោងប្រហែល ០៥រសៀលបានខ្លួនទាំង ០៣នាក់ចេញពី

ព្រៃមកវិញ ចាប់សេកពុំបាន ។ ខ្លួនក៏បានបបួលឈ្មោះ គ ឡ និង ឈ្មោះ អ ឆ ទៅយកគោរបស់មាខ្លួនលក់ចែកប្រាក់គ្នា ។ រកគោឃើញ ខ្លួនដឹកយកគោឈ្មោល ០១ក្បាល, ញី ០១ក្បាល ។ ឈ្មោះ គ ឡ ចាប់យកគោ ០១ក្បាល និង ឈ្មោះ អ ឆ យក ០១ក្បាលដែរ រួចដឹកគោកាត់តាមព្រៃ ហើយសំរាកក្នុងព្រៃមួយយប់ ។ លុះព្រឹកឡើងបានបន្តដឹកគោទៅទៀតរហូតដល់ភូមិពង្រក៏ឈប់សំរាកនៅក្បែរផ្ទះឈ្មោះ ស ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង ។

ជនជាប់ចោទឈ្មោះ គ ឡ បានឆ្លើយថា កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ វេលាម៉ោង ០៧ព្រឹក ឈ្មោះ អ ឆ, ឈ្មោះ អ អ និង ខ្លួនបានបបួលគ្នាចូលទៅក្នុងព្រៃអូរអកអំបុក ស្ថិតនៅក្នុងភូមិបុស្ស រកចាប់សត្វសេក ។ លុះល្ងាចឡើងម៉ោងប្រហែល ០៥រសៀល ខ្លួនទាំង ០៣នាក់ខាងលើមកវិញចាប់សេកពុំបាន ។ ក៏ឈ្មោះ អ អ បបួលខ្លួន និង ឈ្មោះ អ ឆ ទៅយកគោរបស់ឪពុកមាវាលក់ចែកប្រាក់គ្នា ។ រកឃើញគោក្បែរព្រៃ ឈ្មោះ អ អ ចាប់ដឹកគោឈ្មោល ០១ក្បាល, ញី ០១ក្បាល ។ ខ្លួនចាប់ដឹកគោ ០១ក្បាល និង ឈ្មោះ អ ឆ យក ០១ក្បាលដែរ ។ ចំពោះគោញី ០១ក្បាលទៀត វាដើរតាមនៅពេលដឹកគោទាំង ០៤ក្បាលនោះ ។ ពួកខ្លួនទាំងបីនាក់ដឹកគោកាត់តាមព្រៃសំរាកក្នុងព្រៃ ០១យប់ ។ លុះព្រឹកឡើងបន្តដឹកទៅដល់ភូមិពង្រ ក៏ឈប់សំរាកនៅក្បែរផ្ទះឈ្មោះ ស ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

ដើមបណ្តឹងរដ្ឋប្បវេណីជាជនរងគ្រោះឈ្មោះ ខ ជ បានឆ្លើយថា កាលពីថ្ងៃមិនចាំ ខែ កុម្ភៈ ឆ្នាំ ២០០៦ វេលាម៉ោង ០៧ព្រឹកឈ្មោះ អ ឆ បានចេញពីផ្ទះ ហើយបានប្រាប់ខ្លួនថា ទៅរកចាប់សត្វសេក ។ ក្រោយមកទើបមាននគរបាលបានប្រាប់ខ្លួនថា ឈ្មោះ ឆ, ឈ្មោះ គ ឡ និង ឈ្មោះ អ អ លួចគោរបស់ខ្លួន ដែលខ្លួនលែងចោលអោយស៊ីស្មៅ ។ គោខ្លួនមានចំនួន ០៥ក្បាល ញី ០៣ក្បាល និង ឈ្មោល ០២ក្បាល ហើយខ្លួនបានទទួលគោវិញគ្រប់ចំនួនហើយ ហើយខ្លួនមិនប្តឹងទាមទារសំណងជម្ងឺចិត្តអ្វីទេ ពីព្រោះអ្នកទាំង ០៣នាក់ជាប្អូនបង្កើតរបស់ខ្លួន ។ ថា ជនជាប់ចោទទាំង ០៣នាក់ជាក្មេងពុំដែលធ្លាប់ប្រព្រឹត្តអំពើខុសច្បាប់ទេកន្លងមក សូមតុលាការមេត្តាអនុគ្រោះទោសដល់ពួកវាផង ព្រោះជនជាប់ចោទជាប់សាច់ញាតិនឹងខ្លួន ។

សាក្សីឈ្មោះ ឃ ឈ បានឆ្លើយថា គោដែលឈ្មោះ អ ឆ, អ អ, និង គ ឡ បានលួចកាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ មិនមែនជាគោរបស់ខ្លួនទេ ។ ឈ្មោះ ឆ, អ និង ឡ គឺក្មួយៗរបស់ខ្លួន គោនោះគ្រាន់តែដូចគោរបស់ខ្លួន ហើយក្មួយវាច្រឡំស្មានតែគោខ្លួនប៉ុណ្ណោះ ។ គោទាំងប្រាំនេះ ជាគោរបស់ឈ្មោះ ខ ជ ទាំងអស់ ហើយឈ្មោះ ខ ជ ជាអ្នកទៅទទួលយកគោពីនគរបាលស្រុកចុងកាល ។

ឈ្មោះ ឃ ឃ ឪពុកជនជាប់ចោទឈ្មោះ គ ឡ បានឆ្លើយថា កូនរបស់ខ្លួនកើតនៅឆ្នាំម្សាញ់ ខែពិសាខ ហើយខ្លួនចាំថា នៅពេលកងទ័ពវៀតណាមដកចេញពីកម្ពុជា វាមិនទាន់កើតទេ ។ លុះដល់ទ័ពវៀតណាមដកបាន ០២ឆ្នាំ ទើបវាកើត ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

ឆ្លងតាមសវនាការនេះ ជនជាប់ចោទទាំង ០៣នាក់ ពិតជាបានប្រព្រឹត្តអំពើប្លន់ប្រាកដមែន ។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និង ជាពិសេសធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ ។

ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

មេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទទាំង ០៣នាក់បានសារភាព

អស់ហើយនូវអំពើប្រព្រឹត្តនេះ ប៉ុន្តែសូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ជនជាប់ចោទទាំង ០៣នាក់នេះផង ពីព្រោះជនជាប់ចោទជាអនីតិជន ហើយគោទាំងអស់ពុំមានបាត់បង់អ្វីទេ ។ ម្យ៉ាងទៀតជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ។

ហេតុនេះសូមតុលាការ មេត្តាជួយបន្ធូរបន្ថយទោសដល់ជនជាប់ចោទផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ
-ក្រោយពីបានពិនិត្យភស្តុតាង
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ជនជាប់ចោទឈ្មោះ អ ខ. ឈ្មោះ អ អ និង ឈ្មោះ គ ឡ បបួលគ្នាទៅចាប់ដឹកគោញី ០៣ក្បាល. គោឈ្មោល ០២ក្បាលរបស់ឈ្មោះ ទ ជ ដែលលែងចោលអោយស៊ីស្មៅប្រុងយកទៅលក់ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន ។ ជនជាប់ចោទទាំង ០៣នាក់មានចេតនាយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិ និង ចាត់ចែងលក់ ។ ប៉ុន្តែបើពិនិត្យបានដិតដល់ឃើញថាជនជាប់ចោទទាំង ០៣នាក់ជាអនីតិជនខ្វះការពិចារណា និង ទើបប្រព្រឹត្តបទល្មើសជាលើកដំបូង ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំងបីនាក់មានចែង និង ផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ឪពុកបង្កើតរបស់ឈ្មោះ គ ឡ បានឆ្លើយនាពេលសវនាការថា កូនកើតឆ្នាំម្សាញ់ អាយុ ១៧ឆ្នាំ ខ្លួនចំណាំថា កូនកើតក្រោយកងទ័ពវៀតណាមដកពីកម្ពុជា ០២ឆ្នាំ ចម្លើយច្បាស់លាស់គួរឱ្យជឿបានថាឈ្មោះ គ ឡ ពិតជាអាយុ ១៧ឆ្នាំ ។

-មាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ មានចែងអំពីស្ថានសំរាលទោសដល់ជនជាប់ចោទជាអនីតិជន ។

-ជនរងគ្រោះឈ្មោះ ទ ជ បានទទួលគោគ្រប់ចំនួនវិញហើយ មិនប្តឹងទាមទារសំណងជម្ងឺចិត្តទេ នោះតុលាការគប្បីមិនពិចារណាដល់បញ្ហានេះឡើយ ។

**ហេតុដូច្នេះវិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោស :

ក-ឈ្មោះ គ ឡ ដាក់គុកកំណត់ ០២ឆ្នាំ ០៦ខែ គិតពីថ្ងៃឃុំខ្លួន

ខ-ឈ្មោះ អ អ ដាក់គុកកំណត់ ០២ឆ្នាំ ០៦ខែ គិតពីថ្ងៃឃុំខ្លួន

គ-ឈ្មោះ រេ ឆ ដាក់គុកកំណត់ ០២ឆ្នាំ ០៦ខែ គិតពីថ្ងៃឃុំខ្លួន

ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិបុស្ស ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ និង មាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខតូភាគី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ** |
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| [redacted] | [redacted] |